# សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និងអង្គការសុខភាពពិភពលោក
# ការរកឃើញករណីទី១០នៃជំងឺផ្តាសាយបក្សីលើមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ,ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១០

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសូមជំរាបជូនដល់ សាធារណៈជនជ្រាបថា បុរសអាយុ ២៧ ឆ្នាំ ម្នាក់ ដែលមានទីលំនៅក្នុងស្រុក កំពង់លាវ ខេត្តព្រៃវែង បានស្លាប់ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ បណ្តាលមកពីមានជំងឺសួតធ្ងន់ធ្ងរ បន្ទាប់ពីបានឆ្លងមេរោគផ្តាសាយបក្សី H5N1 ។ បុរសនេះជាករណីទី ១០ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានឆ្លងជំងឺផ្តាសាយបក្សី និងជាករណីទី ៨ ដែលបានស្លាប់ដោយសារជំងឺនេះ ។

អ្នកជំងឺបានចាប់ផ្តើមឈឺដោយមានរោគសញ្ញា គ្រុនក្តៅ នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០ និងបន្ទាប់មកបានបញ្ជូនទៅព្យាបាលនៅគ្លីនិកមួយ នៅថ្ងៃទី ១៦ មេសា ដោយមានរោគសញ្ញា ក្អក និង ដង្ហើមថប់ ។ អ្នកជំងឺនេះត្រូវបានបញ្ជូនបន្តទៅមន្ទីរពេទ្យ កាល់ម៉ែត នៅថ្ងៃទី ១៧ ខែ មេសា ដោសារស្ថានភាពជំងឺមានភាពធ្ងន់ធ្ងរ ហើយត្រូវបានបញ្ជូនជាបន្ទាន់ទៅបន្ទប់សង្គ្រោះបន្ទាន់ដើម្បីធ្វើការព្យាបាល តែត្រូវបានបាត់បង់ជីវិតដោយជំងឺធ្ងន់ធ្ងរពេក ។ វត្ថុវិភាគដែលបានយកមកពិនិត្យនៅវិទ្យាស្ថានប៉ាស្ទ័រ រកឃើញថាមានវិជ្ជមានមេរោគផ្តាសាយបក្សី H5N1 ។

ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានប្រសាសន៍ថា ជំងឺផ្តាសាយបក្សី H5N1 នៅតែបន្តគំរាមកំហែងដល់សុខភាពប្រជាពលរដ្ឋកម្ពុជា ខ្ញុំសូមរំលឹកប្រជាជនទាំងអស់ត្រូវតែបន្តតាមដាន និង រាយការណ៍សត្វបក្សី ឈឺ ឬងាប់ ទៅក្រសួងសុខាភិបាល និង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ តាមរយៈប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ឬ ការធ្វើដូច្នេះអាចឱ្យមន្ត្រីជំនាញធ្វើការអង្កេតស្រាវជ្រាវ មុនពេលប្រជាជនឆ្លងជំងឺនេះ ។

ជំងឺផ្តាសាយបក្សី H5N1 គឺជាជំងឺមួយដែលជាធម្មតាចំលងរវាងសត្វបក្សីឈឺ ទៅបក្សីផ្សេងទៀត ប៉ុន្តែជួនកាលវាអាចចំលងពីបក្សីទៅមនុស្ស តែវាមិនងាយឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទេ ។ ជំងឺផ្តាសាយបក្សី លើមនុស្ស ជាជំងឺធ្ងន់ធ្ងរ ដែលតំរូវឱ្យមានការធ្វើការព្យាលនៅមន្ទីរពេទ្យ ។ ជំងឺផ្តាសាយបក្សី ខុសពីជំងឺផ្តាសាយថ្មី H1N1 ដែលមនុស្សភាគច្រើនមានជំងឺស្រាល ដូចនឹងជំងឺផ្តាសាយតាមរដូវ ។ ជំងឺផ្តាសាយថ្មី H1N1 ងាយឆ្លងពីមនុស្សទៅមនុស្ស ដូច្នេះមនុស្សភាគច្រើន នឹងងាយឈឺ ប៉ុន្តែអ្នកជំងឺភាគច្រើននឹងជា ដោយឯកឯង ដោយមិនចាំបាច់ព្យាបាល ។

ជាផ្នែកមួយនៃការងារជាប្រចាំរបស់ក្រសួងសុខាភិបាលក្នុងការឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺ ក្រុមឆ្លើយតបបន្ទាន់កំពុងអង្កេតស្រាវជ្រាវដល់ ទីកន្លែងកើតហេតុនៅឯមូលដ្ឋាន ដើម្បីរុករកអ្នកប៉ះពាល់ជិតស្និទ្ធជាមួយអ្នកជំងឺ និងចាប់ផ្តើមផ្តល់ឱសថបង្ការដែលចាំបាច់ ។ យុទ្ធនាការ អប់រំសុខភាពកំពុងត្រូវបានដំណើរការអនុវត្ត ដើម្បីជំរាបជូនដល់ សមាជិកក្រុមគ្រួសារ នូវរបៀបបង្ការការចំលងជំងឺផ្តាសាយបក្សី ។ សារអប់រំទាំងនោះរួមមាន : លាងដៃ ឱ្យបានញឹកញាប់ , រៀបចំ

អាហារដោយមានសុវត្ថិភាព, ដាក់ កុមារនៅឆ្ងាយពីសត្វបក្សី, ដាក់ សត្វបក្សីនៅឱ្យឆ្ងាយពីកន្លែងរស់ នៅ និង កុំបរិភោគសត្វបក្សីឈឺ ឬ ងាប់ ។

មន្ត្រីសុខាភិបាលកំពុងសហការជាមួយមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលកំពុងធ្វើការអង្កេតស្រាវជ្រាវអំពីរបាយការណ៍បក្សីស្លាប់នៅក្នុងភូមិដែលមានការរាតត្បាត ។

មកទល់ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១០ នេះ នៅព្រះរាជាណាចក្រកម្ពុជា ករណីជំងឺផ្តាសាយបក្សីលើមនុស្ស H5N1 មានចំនួន ១០ ករណី ដែលក្នុងនោះ ៨ ករណីបានស្លាប់ ។ ចំពោះស្ថានភាពពិភពលោកវិញចាប់តាំងពីឆ្នាំ ២០០៣ មានករណីសរុបទាំងអស់ ៤៩៤ និង ក្នុងនោះមាន ២៩៣ នាក់បានស្លាប់ ។

ក្រសួងសុខាភិបាលនឹងបន្តធ្វើការជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍របស់ជំងឺនេះ តាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ។

សំរាប់ពត៌មានបន្ថែមអំពីជំងឺនេះ សូមទាក់ទងទូរស័ព្ទទាន់ហេតុការណ៍ :

**១១៥ ( មិនគិតថ្លៃ), ០១២ ៤៨៨៩៨១, ០៨៩ ៦៦៩៥៦៧**

សំរាប់ពត៌មានបន្ថែមទៀតសូមធ្វើការទាក់ទង:

**ក្រសួងសុខាភិបាល :**

វេជ្ជ. **សុខ ទូច : ០១២ ៨៥៦ ៨៤៨**

វេជ្ជ. **លី សុវ៉ាន់ : ០១២ ៨២៥ ៤២៤**

**អង្គការសុខភាពពិភពលោក :**

វេជ្ជ. **គីតធី វ៉ាន់ ម៉ារ៉ែន : ៨៥៥ ២៣ ២១៦ ៦១០**

វេជ្ជ. **អាសហ្គារី នីម៉ា : ៨៥៥ ២៣ ២១៦ ៦១០**